E103

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឲ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬអត់ និង សំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 06 / 2011
ម៉ោង (Time/Heure): 15:28
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំផ្លាស់ប្តូរការកំណត់បទចោទនៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬអត់ ។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះសហព្រះរាជអាជ្ញាបានលើកឡើងសំណើនានា[1] ទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ដែលហួសពីកាលបរិច្ឆេទកំណត់ឱ្យលើកឡើង[2] ។ សេចក្តីសម្រេចជាបន្ទាន់នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង និង ភាគីទាំងអស់ ពីព្រោះថាបើសិនសំណើនានារបស់សហព្រះរាជអាជ្ញា មិនអាចទទួលបាន នោះគេមិនត្រូវការបន្ថែមពេលវេលាដើម្បីលើកបញ្ហាឡើងបញ្ហាទាំងនេះទេ ។ ធ្វើយ៉ាងដូច្នេះ គឺដើម្បីកុំឱ្យមេធាវីការពារក្តីទទួលរងនូវប៉ះពាល់ដោយសារភាពយឺតយ៉ាវរបស់សហព្រះរាជអាជ្ញា ក្នុងការលើកឡើងបញ្ហាទាំងនេះ ។ មេធាវីការពារក្តីស្នើសុំបន្ថែមថា អង្គជំនុំជម្រះសាលាដំបូង ផ្តល់ពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើនានារបស់ កសព (បើសិនជា អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាសំណើទាំងនេះអាចទទួលយកបាន) រហូតដល់ ២២ សីហា ២០១១។ ការបន្ថែមពេលវេលានេះគឺមានលក្ខណៈចាំបាច់ ដោយហេតុថា កសព មានពេលរហូតដល់ទៅជាង ៥ ខែដើម្បីត្រៀមរៀបចំនូវសំណើរបស់ខ្លួន ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងមានពេលរហូតដល់ជាង ១ឆ្នាំ ដើម្បីត្រៀមរៀបចំនូវសំណើរបស់ខ្លួនទាក់ទង JCE ។ មេធាវីការពារក្តី ត្រូវតែមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងសំណើសុំទាំងនេះ។

## I សាវតារ

១. កាលពីថ្ងៃទី ២០ ឧសភា ២០១១ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា JCE III មិនត្រូវបានគេ

---

[1] សូមមើលសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១, E95 (សំណើជម្លោះប្រដាប់អាវុធCAH)។ ។ សំណើរបស់សហព្រះរាជអាជ្ញាសុំអោយអង្គជំនុំជម្រះសាលាដំបូង កែប្រែការកំណត់បទចោទទៅលើអង្គហេតុបង្កើតជាអំពើរំលោភសេពសន្ថវៈ ដែលធ្វើអោយអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាង អំពើអមនុស្សធម៌ផ្សេងទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៦ មិថុនា ២០១១ ឯកសារលេខ E99 ("សំណើរំលោភសេពសន្ថវៈCAH")។ សំណើរបស់សហព្រះរាជអាជ្ញាសុំអោយអង្គជំនុំជម្រះសាលាដំបូងពិចារណាថា JCE III ជាទម្រង់នៃការទទួលខុសត្រូវមួយផ្សេងទៀត ចុះថ្ងៃទី ១៧ មិថុនា ២០១១ ("សំណើទាក់ទងនឹងJCE") (និយាយជារួមហៅថា "សំណើនានារបស់ កសព") ។

[2] សូមមើលវិធាន ៨៩ នៃវិធានផ្ទៃក្នុងនៃ អវតក ("វិធាន") ។

ទទួលស្គាល់ថាជាទម្រង់មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយក្នុងឆ្នាំ ១៩៧៥-៧៩ ហើយមិនអាចយកមកអនុវត្តនៅ អវតក ឡើយ[3]។

២. កាលពីថ្ងៃទី ១៣ មករា ២០១១ អង្គបុរេជំនុំជម្រះ បានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ ដែលក្នុងនោះបានទទួលយកដោយផ្នែកនូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយចំនួនរបស់មេធាវីការពារក្តី ជាអាទិ៍៖

មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានពុំបានធ្វើការពិចារណាថា ក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អវតក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវអោយមានចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ ត្រូវបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងផ្នែក IV(ក) ជំពូកបី នៃដីកាដំណោះស្រាយ។

មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ(ឆ) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយ "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត")[4]។

៣. កាលពីថ្ងៃទី ១៤ មករា ២០១១ អង្គជំនុំជម្រះសាលាដំបូង បានទទួលនូវសំណុំរឿង។ នេះជាចំណុចចាប់ផ្តើម ពេលវេលាសម្រាប់ដាក់អញ្ញត្រកម្ម ដែលធ្វើអោយពេលវេលាកំណត់ដើមសម្រាប់ដាក់

---

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ឧសភា ២០១១ ឯកសារលេខ D97/14/15 កថាខណ្ឌ ៧៧-៨៨។

[4] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26។

អញ្ញត្រកម្មបែបនេះចប់ត្រឹមថ្ងៃទី ១៥ កុម្ភៈ ២០១១[5]។

៤. កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីបញ្ហាផ្នែកច្បាប់នានាដែលខ្លួនមានបំណងលើកឡើងនៅសវនាការបឋម[6]។ តាមរយៈបញ្ជីនេះ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញាមានបំណង *"ស្នើសុំឱ្យធ្វើការផ្លាស់ប្តូរការកំណត់បទចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសាលក្រម ដើម្បីដាក់បញ្ចូល*(ក) ជម្លោះប្រដាប់អាវុធមិនចាំបាច់តម្រូវឱ្យបង្ហាញសក្ខីកម្មថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ (ខ) ការរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (គ) ការប្រព្រឹត្តបទឧក្រិដ្ឋនានាដោយទម្រង់ III នៃសហឧក្រិដ្ឋកម្មរួម (*វិធាន៩៨*")[7] ។

៥. កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ការសង្កេតចំពោះបញ្ជីបញ្ហាច្បាប់របស់សហព្រះរាជអាជ្ញា[8] ។ មេធាវីការពារក្តីបានលើកឡើងថា៖

> សហព្រះរាជអាជ្ញា ត្រូវតែលើកឡើងពីបញ្ហាទាំងនេះក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ ។ ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានធ្វើដូច្នេះឡើយ ហើយដូច្នេះឥឡូវនេះ ពេលវេលាមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាលើកឡើងពីបញ្ហាយុត្តាធិការទាំងនេះឡើយ ។ បើទោះបីជាបញ្ហានេះនៅតែអាចលើកឡើងក៏ដោយ ប៉ុន្តែវិធាន៩៨ នៃវិធានផ្ទៃក្នុង មិនអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការផ្លាស់ប្តូរការកំណត់បទចោទដែរ ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សហព្រះរាជអាជ្ញាអាចលើកពីបញ្ហាទាំងនេះនៅសវនាការបឋម នោះមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យសហព្រះរាជអាជ្ញា ផ្តល់សារណាជាលាយលក្ខណ៍អក្សរពិស្តារនៅមុនពេលសវនាការបឋម ដោយធ្វើការពន្យល់ពីមូលហេតុដែលនាំឱ្យមានការផ្លាស់ប្តូរការកំណត់

---

[5] *សូមមើល*ដីកាបង្គាប់អោយដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី ១៧ មករា ២០១១ ឯកសារលេខ E9។

[6] សេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីបញ្ហាផ្នែកច្បាប់នានាដែលខ្លួនមានបំណងលើកឡើងក្នុងសវនាការបឋម, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១, ឯកសារ E9/30។

[7] សេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញាអំពីបញ្ហាផ្នែកច្បាប់នានាដែលខ្លួនមានបំណងលើកឡើងក្នុងសវនាការបឋម, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១, ឯកសារ E9/30។

[8] ការសង្កេតរបស់លោក អៀង សារី លើសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាផ្នែកច្បាប់ដែលខ្លួនមានបំណងលើកឡើងនៅសវនាការបឋម,ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១, ឯកសារ E9/30/1។

បទចោទទាំងនេះ ហើយបន្ទាប់មកផ្តល់ឱកាសឲ្យមេធាវីការពារក្តីដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរ[9] ។

៦. កាលពីថ្ងៃទី១១ ខែឧសភា អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយទាក់ទងនឹងកាលបរិច្ឆេទបើកសវនាការបឋម ដោយបានរាយបញ្ជីបញ្ហាដែលត្រូវលើកយកមកពិភាក្សានៅសវនាការបឋមនេះ និងមិនបានដាក់បញ្ចូលបញ្ហាដែលលើកឡើងនៅក្នុង *"សំណើរបស់សហព្រះរាជអាជ្ញា សុំផ្លាស់ប្តូរការកំណត់បទចោទ "* ឡើយ ។ អនុស្សរណៈនេះ បានបញ្ជាក់ថា៖

> នៅសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងនឹងមិនស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់ទាក់ទងនឹងបញ្ហាណាមួយ ក្រៅតែពីបញ្ហាដែលបានបញ្ជាក់ខាងលើទេ ។ បញ្ហានេះ គឺដោយសារតែអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាបញ្ហាដទៃទៀតដែលបានលើកឡើងដោយភាគីនៅក្នុងសេចក្តីសន្និដ្ឋានផ្សេងៗរបស់ពួកគេ គឺ
>
> -ត្រូវបានសម្រេចរួចជាស្រេចហើយដោយអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលកិច្ចប្រជុំរៀបចំសវនាការ និងសេចក្តីសម្រេចបន្ទាប់របស់ខ្លួនលេខ (E74) ឬ
>
> -ត្រូវរង់ចាំសេចក្តីណែនាំបន្ថែមទៀតពីអង្គជំនុំជម្រះសាលាដំបូងក្នុងពេលវេលាមួយសមស្រប ឬ
>
> -អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយភាគីក្នុងអំឡុងពេលជំនុំជម្រះប្រសិនបើពាក់ព័ន្ធ និងប្រសិនបើចាំបាច់[10]។

អង្គជំនុំជម្រះសាលាដំបូងមិនពន្យល់ថា តើអង្គជំនុំជម្រះបានពិចារណាលើបញ្ហានានាដែលបានលើកឡើងនៅក្នុងសំណើររបស់សហព្រះរាជអាជ្ញា *"សុំឱ្យផ្លាស់ប្តូរការកំណត់បទចោទ"* ដើម្បីនៅស្ថិតនៅក្នុងជំពូកទីពីរ ឬទីបី ។

៧. កាលពីថ្ងៃទី១៨ ខែឧសភា សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតប"[11] ទៅនឹងការសង្កេតរបស់

---

[9] ដូចជើងទំព័រខាងលើ, បើកចំហរ (ការដកស្រង់ផ្ទៃក្នុងត្រូវលុបចោល)។

[10] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ កាលបរិច្ឆេទសវនាការបឋម, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១, ឯកសារ E86។

[11] គួរកត់សម្គាល់ថាអង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់មេធាវីការពារក្តីថា អង្គជំនុំជម្រះចាត់ទុកសេចក្តីសន្និដ្ឋានបែបនេះថា ជាសារណាឆ្លើយតប មិនមែនជាចម្លើយតបឡើយ ដូច្នេះហើយការដាក់សេចក្តីសន្និដ្ឋានេះ មិនត្រូវបានទទួលយក និងដាក់នៅក្នុងសំណុំរឿងឡើយ ពីព្រោះកាលពីមុនអង្គជំនុំជម្រះសាលាដំបូងមិនបានចេញការអនុញ្ញាតឱ្យដាក់ការឆ្លើយតបឡើយ ។ សូមមើលសារអេឡិចត្រូនិចរបស់លោកស្រី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើទៅកាន់ក្រុមមេធាវីការពារក្តីលោក អៀង សារី និង **សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថាតើសហព្រះរាជអាជ្ញាសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទឡើងវិញនៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬអត់ និង សំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់**

មេធាវីការពារក្តីកាលពីថ្ងៃទី៣ ខែឧសភាឆ្នាំ២០១១[12]។ ចម្លើយតបនោះ លើកឡើងថា៖

សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីថា ខ្លួននឹងដាក់សារណាស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសាលក្រម...។ សហព្រះរាជអាជ្ញាមានបំណងដាក់សារណានេះនៅមុនសវនាការបឋម ឬយ៉ាងយូរបំផុតនៅមុនសវនាការលើអង្គសេចក្តី ។ ធ្វើដូច្នេះ នឹងផ្តល់ឱកាសឱ្យមេធាវីការពារក្តីទាំងអស់ ធ្វើការឆ្លើយតបដូចជាអំពីភាពដែលអាចទទួលយកបាន និងអង្គសេចក្តីដែលមាននៅក្នុងសំណើនេះ ដូចដែលមេធាវីការពារក្តីបានលើកឡើងក្នុងញត្តិរបស់ពួកគេដែរ[13]។

៨. កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ មេធាវីការពារក្តីបានក្រើនរំលឹកអង្គជំនុំជម្រះសាលាដំបូង (តាមរយៈលិខិតមួយច្បាប់ដែលបានចម្លងជូនភាគីទាំងអស់)ពីក្តីកង្វល់ជាក់លាក់ រួមទាំងស្ថានភាពនៃសេចក្តីសន្និដ្ឋានដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ III និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[14]។ នៅក្នុងលិខិតនោះ មេធាវីការពារក្តីបានបញ្ជាក់ជាថ្មីម្តងទៀតនូវគោលជំហររបស់ខ្លួនដែលថា សហព្រះរាជអាជ្ញាមិនអាចដាក់សំណើសុំផ្លាស់ប្តូរការកំណត់បទចោទបានឡើយ ព្រោះបញ្ហានេះវាហួសពេលវេលាកំណត់រួចទៅហើយ ។ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចេញដីកាសម្រេចមួយទាក់ទងនឹងបញ្ហានេះ ។ ដោយពិចារណាពីភាពមមាញឹកនៅមុនសវនាការបឋម និងមុនសវនាការលើអង្គសេចក្តី មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់ចម្លើយតប និងអនុញ្ញាតឱ្យមេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតប បើសិនអង្គជំនុំជម្រះអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់

---

ភាគីដទៃទៀត, ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១១ ដែលនៅក្នុងសារអេលឡិចត្រូនិចនោះបញ្ជាក់ថា ចម្លើយតបចំពោះការសង្កេតរបស់ភាគីដទៃទៀតចំពោះញត្តិណាមួយ នឹងត្រូវចាត់ទុកជាសារណាឆ្លើយតប មិនមែនជាចម្លើយតបឡើយ ។

[12] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការសង្កេតចំពោះសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាផ្នែកច្បាប់នានាដែលខ្លួនមានបណងលើកឡើងក្នុងសវនាការបឋម, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១, ឯកសារ E9/30/2។

[13] *ដូចជើងទំព័រខាងលើ* កថាខណ្ឌទី៣ដល់៤។ កសព ក៏បានលើកឡើងដែរថា សំណើរបស់ខ្លួនសុំផ្លាស់ការកំណត់បទចោទ មិនអាចត្រូវបានចាត់ទុកថាជាអញ្ញត្រកម្មបឋមឡើយ។ ដូចខាងលើ, កថាខណ្ឌទី៥ ដល់ទី៦។

[14] លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើទៅកាន់អង្គជំនុំជម្រះសាលាដំបូង៖ សំណើសុំព័ត៌មានទាក់ទិននឹងសារណាបន្ថែមស្តីពីអញ្ញត្រកម្មមួយចំនួន, របៀបវារៈ និងព័ត៌មានស្តីពីសវនាការបឋម និងស្ថានភាពនៃសេចក្តីសន្និដ្ឋានដែលបានលើកឡើងដោយ កសព ទាក់ទងនឹង សហឧក្រិដ្ឋកម្មរួមទម្រង់ III និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១។

**សំណើរបស់ អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថាតើសហព្រះរាជអាជ្ញាសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទឡើងវិញនៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬអត់ និង សំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់**

សេចក្តីសន្និដ្ឋានដែលសហព្រះរាជអាជ្ញាបានស្នើសុំ[15] ។

៩. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ កសព បានដាក់សំណើជម្លោះប្រដាប់អាវុធCAH ។ សំណើនេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៦ មិថុនា ឆ្នាំ២០១១ ។

១០. កាលពីថ្ងៃទី ១៦ មិថុនា កសព បានដាក់សំណើរំលោភសេពសន្ថវៈCAH។ នៅថ្ងៃទី ១៧ មិថុនា ២០១១ កសព បានដាក់សំណើទាក់ទង JCE ។ សំណើទាំងពីរនេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៣ មិថុនា ២០១១។

១១. នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង បានផ្ញើសារអេឡិចត្រូនិកមួយទៅកាន់ភាគីទាំងអស់ ដែលមានខ្លឹមសារថាក្រុមការពារក្តីទាំងអស់[16] មានពេលរហូតដល់ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០១១ ដើម្បីដាក់ចម្លើយតបទៅនឹងសំណើនានារបស់ កសព ហើយថាកសព និងដើមបណ្តឹងរដ្ឋប្បវេណី[17] មានរយៈពេល ១០ ថ្ងៃ ដើម្បីឆ្លើយតប[18] ។

## II សំណើសុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់

១២. មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចបន្ទាន់ ទាក់ទងទៅនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចលើកឡើងបញ្ហាទាក់ទងយុត្តាធិការរបស់អង្គជំនុំជម្រះនៅដំណាក់កាលនេះនៃនីតិវិធីបានដែរ ឬអត់ ឬត្រូវចាត់ទុកថាសហព្រះរាជអាជ្ញាបានលះបង់សិទ្ធិក្នុងការលើកឡើងបញ្ហានេះនៅពេលនេះដែរ ឬយ៉ាងណា ។ សេចក្តីសម្រេចនេះនឹងជួយដល់អង្គជំនុំ

---

[15] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី៣។

[16] សូមកត់សម្គាល់ថាវាមិនមែនតែក្រុមមេធាវីការពារក្តីតែឯងទេដែលអាចជ្រើសយកការឆ្លើយតបទៅនឹងសំណើរបស់ កសព សុំឱ្យផ្លាស់ប្តូរការកំណត់បទចោទជាថ្មីដែលមាននៅក្នុងដីកាដំណោះស្រាយ រួមទាំង JCE ផងដែរ ។ ដើម្បីបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី ០០២ មានជំទាស់ទៅនឹងការអនុវត្តនៅ អវតក នៃ JCE III ផងដែរ ។ សូមមើលចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ D97/3/4 ។

[17] សូមកត់សម្គាល់ថា បើទោះបីខ្លឹមសារនៃសារអេឡិចត្រូនិកបញ្ជាក់ន័យយ៉ាងម្តេចក៏ដោយចុះ ក៏ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិដាក់សារណាឆ្លើយតបនោះទេ ដោយសារតែពួកគេមិនមែនជាភាគីដែលដាក់សំណើដើម។ មានតែសហព្រះរាជអាជ្ញាទេដែលអាចឆ្លើយតបទៅនឹងចម្លើយតបដោយផ្ទាល់ទៅនឹងសារណារបស់ កសព ។

[18] សារអេឡិចត្រូនិកពី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើទៅភាគីទាំងអស់ ។ ការកែប្រែកាលបរិច្ឆេទដែលស្នើឡើងដោយអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការរកឃើញរបស់ព្រះរាជអាជ្ញានាពេលថ្មីៗនេះ ។ ការជូនដំណឹងជាមុននៃកាលបរិច្ឆេទកំណត់សម្រាប់ដាក់ឯកសារ/បញ្ជីភស្តុតាងបន្ថែម(សម្រាប់ជំហានទីមួយនៃការជំនុំជម្រះ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ។

ជម្រះសាលាដំបូង មេធាវីការពារក្តី និងភាគីទាំងអស់ ។ បើសិនអង្គជំនុំជម្រះយល់ឃើញថា សំណើរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាន នោះក្រុមការពារក្តីទាំងអស់ និងប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ នឹងមិនខ្ជះខ្ជាយពេលវេលាដោយឥតប្រយោជន៍នៃពេលវេលាដែលនៅសេសសល់របស់ពួកគេ ដើម្បីរៀបចំចម្លើយតបទៅនឹងបញ្ហាដែលត្រូវបានរវាំងដោយពេលវេលា ហើយសហព្រះរាជអាជ្ញា និងប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណី[19] មិនត្រូវការពង្រាងសារណាឆ្លើយតបដែរ ។ អង្គជំនុំជម្រះសាលាដំបូងមិនចាំបាច់វិភាគលើខ្លឹមសារនៃសំណើនានារបស់សហព្រះរាជអាជ្ញា ចម្លើយតប និងសារណាឆ្លើយតបដែរ ។

១៣. សេចក្តីសម្រេចបន្ទាន់ដោយបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា នឹងបង្កការប៉ះពាល់ដល់មេធាវីការពារក្តី ដែលបង្កឡើយដោយការដាក់សារណារបស់សហព្រះរាជអាជ្ញាដែលហួសពេលវេលា ។ សេចក្តីសម្រេចបន្ទាន់ គឺចាំបាច់ពីព្រោះមេធាវីការពារក្តីត្រូវតែបានជូនដំណឹងពាក់ព័ន្ធទៅនឹងថា តើបញ្ហានេះអាចត្រូវលើកឡើងនៅដំណាក់កាលនេះដែរ ឬអត់ ។ ប្រសិនបើបញ្ហានេះមិនត្រូវបានរារាំងដោយពេលវេលាទេ ហើយបើសិនជាការបកស្រាយរបស់ កសព លើវិធាន ៩៨ គឺត្រឹមត្រូវ នោះមេធាវីការពារក្តីមានសំណើជាច្រើន សុំឱ្យធ្វើការកំណត់បទចោទឡើងវិញ ដែលមេធាវីការពារក្តីអាចមានបំណងដាក់[20] ។ ការជូនដំណឹងត្រូវតែធ្វើកាន់តែច្រើនកាន់តែប្រសើរ ធ្វើដូច្នេះមេធាវីការពារក្តីអាចរៀបចំសារណាទាំងនេះ ហើយបញ្ហាទាំងនេះអាចត្រូវបានដោះស្រាយនៅមុនពេលការជំនុំជម្រះក្តី។

## <u>ក. សំណើរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបានទេដោយសារសំណើទាំងនេះមិនត្រូវបានលើកឡើងថា ជាអញ្ញត្រកម្មក្នុងរយៈពេល ៣០ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ</u>

---

[19] សូមកត់សម្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅមិនគួរមានសិទ្ធិឆ្លើយតបទៅនឹងចម្លើយតបនានាដែលឆ្លើយឆ្លងផ្ទាល់ទៅនឹងសហព្រះរាជអាជ្ញាឡើយ ប៉ុន្តែ សារអ៊ីម៉ែលចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១១ របស់មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាអនុញ្ញាតឱ្យពួកគេឆ្លើយតបក្នុងឱកាសនេះ ។

[20] ជាឧទាហរណ៍ មេធាវីការពារក្តីអាចដាក់សារណាថា ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង មិនមែនជាបទល្មើសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេល ១៩៧៥-៧៩ ឡើយ ប៉ុន្តែវាអាចត្រូវបានគេពិចារណាថាជា "អំពើអមនុស្សធម៌ផ្សេងទៀត"។ មេធាវីការពារក្តីក៏អាចស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងផងដែរថា ការកំណត់បទចោទលើ JCEI ដើម្បីអោយសមនឹងទម្រង់ប្រហាក់គ្នានៃការប្រព្រឹត្ត នៅក្នុងច្បាប់កម្ពុជាជាធរមាន ឬសូម្បីថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុង ៩១៧៥-១៩៧៩។

១៤. មេធាវីការពារក្ដីយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា ដោយមិនពិចារណាលើអង្គសេចក្ដីរបស់វា ។ វិធាន៨៩ នៃវិធានផ្ទៃក្នុង តម្រូវឱ្យភាគីលើកឡើងបញ្ហាយុត្តាធិការយ៉ាងយូរ (សាមសិប) ៣០ ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ គឺដើម្បីឱ្យអង្គជំនុំជម្រះមានលទ្ធភាពដោះស្រាយបញ្ហាទាំងនេះឱ្យបានគ្រប់ជ្រុងជ្រោយនៅមុនអំឡុងពេលដ៏មមាញឹក ដែលនឹងជិតឈានទៅដល់សវនាការបឋម និងសវនាការលើអង្គសេចក្ដីនៅពេលខាងមុខនេះ[21] ។

១៥. អនុលោមតាមវិធាន ៨៩ បញ្ហាមួយដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ "<u>ត្រូវតែ</u>លើកឡើងយ៉ាងយូរសាមសិប(៣០)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ <u>បើមិនដូច្នេះទេ អញ្ញត្រកម្មនេះមិនអាចត្រូវបានទទួលយកឡើយ</u>"[22] ។ ដីកាដំណោះស្រាយចូលជាស្ថាពរនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១១[23] ដែលធ្វើឱ្យកាលបរិច្ឆេទកំណត់សម្រាប់លើកបញ្ហានេះ គឺនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ។ សហព្រះរាជអាជ្ញាមិនបានលើកបញ្ហាទាំងនេះតាមកាលកំណត់នេះទេ ហើយហេតុដូច្នេះ សហព្រះរាជអាជ្ញាត្រូវបានហាមឃាត់មិនឱ្យលើកបញ្ហានេះនៅពេលនេះឡើយ ។ សហព្រះរាជអាជ្ញា ខកខានមិនបានចាត់ការប្រកបដោយការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ក្នុងការលើកឡើងនូវបញ្ហាទាំងនេះ ភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង និងនៅមុនកាលបរិច្ឆេទកំណត់ដោយវិធានផ្ទៃក្នុងឡើយ[24] ។

---

[21] សូម្បីតែ កសព ក៏បានកត់សម្គាល់ផងដែរថា ពេលវេលានេះគឺជាអំឡុងពេលរវល់ ដោយថាភាគីកំពុង "មមាញឹកជាខ្លាំង" ក្នុងការត្រៀមរៀបចំសវនាការ។ *សូមមើល* សំណើទាក់ទងនឹងJCE កថាខណ្ឌ ៣១។

[22] បញ្ជាក់បន្ថែម ។

[23] "អនុលោមតាមដីការបស់អង្គជំនុំជម្រសាលាដំបូងបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីត្រៀមរៀបចំការជំនុំជម្រះក្ដី (E9) ពេលវេលាកំណត់ដែលចែងនៅក្នុងវិធាន ៨០(១) និង(២) ចាប់ផ្ដើមគិតចាប់ពីថ្ងៃ សុក្រ ទី១៤ ខែមករា ឆ្នាំ២០១១ នេះតទៅ "អនុស្សរណៈអន្តរការិយាល័យពីអ្នកនាង Susan Lamb, មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅភាគីទាំងអស់នៅក្នុងករណី 00២, ការជូនដំណឹងជាមុននៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើញត្តិ E14, E15, E9/2, E9/3, E/24 និង E27, ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១១ នៅទំព័រ ២ ។

[24] សូមមើលសេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំដិតចិត្តចៅក្រម និល ណុន និងសំណើពាក់ព័ន្ធ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ E5/3 នៅកថាខណ្ឌទី២ ដែលអង្គជំនុំជម្រះទទួលស្គាល់កាតព្វកិច្ចនៃការយកចិត្តទុកដាក់ហ្មត់ចត់របស់ភាគី ។ សូមមើលផងដែរ *រឿងក្ដី រដ្ឋអាជ្ញា តទល់* *Delalić et al.*, IT-96-21-A, សាលដីកាចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ នៅកថាខណ្ឌទី ៦៣១ ដែលអង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY យល់ឃើញថា "ការខកខានរបស់មេធាវីការពារក្ដីក្នុងការជំទាស់ ជាធម្មតា

**សំណើរបស់ អៀង សារី សុំឱ្យមានសេចក្ដីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថាតើសហព្រះរាជអាជ្ញាសុំឱ្យផ្លាស់ប្ដូរការកំណត់បទចោទឡើងវិញនៅដំណាក់កាលនេះនៃនីតិវិធី ដែរ ឬអត់ និង សំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់**

00710062



១៦. សហព្រះរាជអាជ្ញាធ្វើការអះអាងថា បញ្ហាយុត្តាធិការដែលខ្លួនប៉ុនប៉ងលើកឡើង គឺមិនមែនជាបញ្ហាអញ្ញត្រកម្មនោះទេ ហើយ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលជំហរនេះនៅក្នុងករណី ០០១[25] ប៉ុន្តែការអះអាងបែបនេះគឺមិនត្រឹមត្រូវ ។ អង្គជំនុំជម្រះគ្រាន់តែគូសបញ្ជាក់ថា អញ្ញត្រកម្មពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការមិនត្រូវបានលើកឡើងនៅសវនាការបឋមនៅក្នុងករណី០០១ឡើយ[26] ។ នេះគឺដោយសារសហព្រះរាជអាជ្ញាអន្តរជាតិ បានផ្តល់យោបល់ដល់អង្គជំនុំជម្រះនៅសវនាការបឋមថា "យើងមិនមានបំណងពិភាក្សា ឬលើកឡើងបញ្ហាផ្លូវច្បាប់ណាមួយ..."[27]។ ការអនុវត្តនូវ JCE ត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញានៅសវនាការបឋមក្នុងករណី ០០១ ប៉ុន្តែជាក់ស្តែងបញ្ហានេះត្រូវបានគេលើកឡើងនៅពេលក្រោយមកទៀតតែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឱ្យលើកឡើងបញ្ហានេះនៅពេលក្រោយមកទៀត ពីព្រោះមេធាវីការពារក្តីរបស់ ឌុច មិនបានជំទាស់ថាបញ្ហានេះមិនបានលើកឡើងឱ្យទាន់ពេលវេលានោះឡើយ (មេធាវីការពារក្តី ឌុច មិនបានលើកឡើងនូវបញ្ហាច្បាប់ជាច្រើននៅដំណើរការនីតិវិធីជំនុំជម្រះក្តី ដូចជាការទាញអំណះអំណាងដែលថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត)[28] ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "សំណើរបស់សហព្រះរាជ

---

នឹងបង្ហាញថាមេធាវីការពារក្តីបង្កើតឱ្យមានការយល់ឃើញនៅពេលនោះថា បញ្ហាដែលចៅក្រមមិនបានយកចិត្តទុកដាក់ មិនមានសារៈសំខាន់ចំពោះរឿងក្តីរបស់គាត់ ដែលនីតិវិធីមិនអាចបន្តបានដោយគ្មានការអំពាវនាវឱ្យយកចិត្តទុកដាក់ឡើយ" ។ គោលការណ៍នេះអនុវត្តចំពោះសហព្រះរាជអាជ្ញា ព្រមទាំងមេធាវីការពារក្តីផងដែរ ។

[25] សូមមើលចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះការអង្កេតរបស់អៀងសារី ទៅនឹងការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងលើកឡើងនៅសវនាការបឋម ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ E9/30/2 នៅកថាខណ្ឌទី៥។

[26] សូមមើលខាងលើ, លេខយោងទី៨ ដែលនិយាយយោងចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលគូសបញ្ជាក់ "អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់ អវតក មិនត្រូវបានគេលើកឡើង នៅសវនាការបឋម ស្របតាមវិធាន ៨៩ ឡើយ ។

[27] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ០០១/១៨-០៧-២០០៧-អវតក/អជសង, ប្រតិចារិត ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៩ E1/3/1 នៅទំព័រ៩ ។

[28] សូមមើល ឧទាហរណ៍, Anne Heidel, សវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលាក្រមប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ អាចរកបាននៅ:http://www.dccam.org/Projects/ECCC_Trial_Observation/pdf/Report_on_Appeal_of_Judgment_in_Case_001_Against_Kaing_Guek_Eav.pdf. "នៅទូទាំងសវនាការ សហមេធាវីរបស់ ឌុច អនុវត្តយុទ្ធសាស្ត្រទទួលយកការចោទប្រកាន់ស្ទើរតែទាំងអស់ ដូចជាសារភាពកំហុសទាំងអស់តាមការចោទប្រកាន់ សម្តែងវិប្បដិសារី និង

អាជ្ញាសុំអនុវត្ត JCE អាចត្រូវបានដាក់នៅក្នុងពេលវេលាសមស្រប និងមានភាពពាក់ព័ន្ធ...”[29]។ សហព្រះរាជអាជ្ញាពិតជាបានដឹងថា ខ្លួនត្រូវបានគេរំពឹងទុកថានឹងដាក់សារណាទាន់ពេលវេលា ។ ប៉ុន្តែដើម្បីធ្វើជាស្នៀត សហព្រះរាជអាជ្ញាបានជ្រើសរើសប្រើកលល្បិចមិនសមរម្យដើម្បីទាញយកផលចំណេញ ។ កសព បានដាក់សំណើសុំបី ក្នុងរយៈពេលតែប៉ុន្មានថ្ងៃនៅមុនពេលចាប់ផ្តើមសវនាការបឋម ហើយនៅពេលពេលដែលភាគីកំពុងត្រៀមរៀបចំសម្រាប់ការចាប់ផ្តើមនូវសវនាការលើអង្គសេចក្តី។ គ្មានអ្វីមករារាំងសហព្រះរាជអាជ្ញាមិនធ្វើសារណាឲ្យទាន់ពេលវេលាឡើយ ។ សហព្រះរាជអាជ្ញា មិនបានផ្តល់ការពន្យល់ណាមួយទាក់ទងនឹងបញ្ហាថាហេតុអ្វីបានខ្លួនមិនអាចធ្វើសកម្មភាពប្រកបដោយវិរៈយភាព ។

**ខ. វិធាន ៩៨ នៃវិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យធ្វើការកំណត់បទចោទឡើងវិញ ដូចដែលសហព្រះរាជអាជ្ញាបានស្នើឡើយ**

១៧. សហព្រះរាជអាជ្ញាលើកវិធាន ៩៨ ធ្វើជាមូលដ្ឋានសម្រាប់ការលើកឡើងបញ្ហាទាំងនេះនៅសវនាការបឋម[30] ។ វិធាន ៩៨(២) ចែងនៅផ្នែកពាក់ព័ន្ធថា: “សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន <u>ប៉ុន្តែមិនអាចបញ្ចូល</u>

---

សហការជាមួយតុលាការក្នុងក្តីសង្ឃឹមថានឹងទទួលបានការបន្ធូរបន្ថយទោស ។ ក្នុងអំឡុងសវនាការ ឌុច និយាយថាគាត់នឹងព្រមទទួលយកការផ្តន្ទាទោសដោយតុលាការ និងមិនប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមទេ ។ វិធីសាស្ត្រនេះត្រូវលែងប្រើក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល គឺនៅពេលដែលសហមេធាវីជាតិរបស់ ឌុច ការ សាវុត្ថ ផ្លាស់ប្តូរយុទ្ធសាស្ត្រដោយបានជំទាស់យុត្តាធិការរបស់តុលាការចំពោះការជំនុំជម្រះ ឌុច និងបានទាញហេតុផលថា ឌុច មិនមានកំហុសទេ ។ នៅមុនការប្រកាសសាលក្រមបន្តិច ឌុច បានបណ្តេញសហមេធាវីអន្តរជាតិ Francois ROUX ជាអ្នកស្ថាបនិកនៃយុទ្ធសាស្ត្រជំនុំជម្រះនេះ ហើយជំនួសដោយសហមេធាវីជាតិ កង រិទ្ធី ។ សហមេធាវីថ្មីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើមូលដ្ឋានថាគ្មានយុត្តាធិការបុគ្គល” ។

[29] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ០០១/១៨-០៧-២០០៧-អវតក/អជសជ, សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ E188 នៅកថាខណ្ឌទី ៥០២ ។

[30] ការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលនឹងត្រូវលើកឡើងនៅក្នុងសវនាការបឋម ចុះថ្ងៃទី ១៩ មេសា ២០១១ ឯកសារ E9/30 នៅទំព័រទី៩ ។

នូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"[31] ។ វិធាននេះយោងទៅលើសមត្ថភាពរបស់អង្គជំនុំជម្រះ ។ វិធាននេះមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាទាញអំណះអំណាងនៅសវនាការបឋមថា សហព្រះរាជអាជ្ញាបានខកខានក្នុងការលើកឡើងនៅក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ ដូចដែលតម្រូវដោយវិធាន ៨៩ ឡើយ។

១៨. បើទោះបីសំណើរបស់សហព្រះរាជអាជ្ញាមិនត្រូវបានគេពិចារណាថាជាអញ្ញត្រកម្មក៏ដោយ សំណើរបស់សហព្រះរាជអាជ្ញានៅតែមិនអាចទទួលយកបានដដែល ដោយសារអង្គជំនុំជម្រះមិនអាចផ្លាស់ប្តូរដែលយកមកអនុវត្តទៅតាមសំណើរបស់សហព្រះរាជអាជ្ញា ។

១៩. ជាបឋមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថាមិនអាចបញ្ចូលធាតុផ្សំថ្មីបានទេ ។ ការដកចេញលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធ អាចពង្រីកវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឱ្យកាន់តែទូលំទូលាយថែមទៀត ហើយអាចនាំឱ្យប៉ះពាល់ដល់ជនជាប់ចោទផងដែរ ។ ហេតុដូច្នេះ វានឹងបង្កឱ្យមានផលប៉ះពាល់យ៉ាងពិតប្រាកដ ដូចគ្នានឹងការបញ្ចូលធាតុផ្សំនៃបទល្មើសផងដែរ ហើយគេត្រូវតែពិចារណាបែបហ្នឹង ។ ការផ្លាស់ប្តូរការកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីបញ្ចូលអំពើរំលោភសេពសន្ថវៈ ថាជាបទល្មើសមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នឹងតម្រូវអោយបន្ថែមនូវធាតុផ្សំនៃបទល្មើសថ្មីមួយទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការផ្លាស់ប្តូរការកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូល JCE III ក៏មិនត្រូវអនុញ្ញាតផងដែរ ដោយសារ JCE III មានធាតុផ្សំខុសគ្នាពី JCE I និង JCEII[32]។

២០. កសព សន្និដ្ឋានដោយផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសិទ្ធិមនុស្សថា ការកំណត់អង្គច្បាប់លើអង្គហេតុអាចជាកម្មវត្ថុនៃការកែប្រែ ហើយថាការអនុវត្តបទដ្ឋានដូចគ្នា, ការបញ្ជាក់ជាថ្មីនៃធាតុផ្សំនៃបទល្មើសមួយ គឺត្រូវបានអនុញ្ញាត[33] ។ កសព ថ្លែងថា "ដំណើរការផ្លាស់ប្តូរនូវការ

[31] បញ្ជាក់បន្ថែម ។

[32] មិនដូចគ្នានឹង JCE I និង JCE II ទេ JEC III មានការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌនៅក្នុងស្ថានភាពដែល "ពាក់ព័ន្ធនឹងគោលបំណងរួម ដើម្បីប្រព្រឹត្តបទល្មើសក្នុងករណីដែលចារីម្នាក់ក្នុងចំណោមចារីជាច្រើននាក់ ប្រព្រឹត្តបទល្មើសមួយដែលនៅក្រៅផែនការរួម គឺជាផលវិបាកដែលអាចព្យាករណ៍បាននៃអនុភាពនៃផែនការរួម" ។ សូមមើល*រឿងក្តីរដ្ឋអាជ្ញា តទល់ Vasiljevic*, IT-98-32, សាលដីកាចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ នៅកថាខណ្ឌទី ៩៩ ។

[33] សំណើជម្លោះប្រដាប់អាវុធCAH នៅកថាខណ្ឌទី ៨ ។

00710065



កំណត់អង្គច្បាប់ទៅលើបទល្មើស តាមលក្ខណៈធម្មជាតិរបស់វា ពាក់ព័ន្ធនឹងការកែប្រែធាតុផ្សំនៃអង្គច្បាប់”[34]។ ការផ្លាស់ប្តូរការកំណត់បទចោទនឹងតម្រូវឱ្យកែប្រែច្បាប់ដែលអនុវត្តនៅ អវតក វិធាន ៩៨(២) មិនត្រូវបានបកស្រាយថាជាការ អនុញ្ញាតឲ្យអង្គជំនុំជម្រះកែប្រែច្បាប់ជាធរមាន ដោយការកំណត់និយមន័យឡើងវិញឡើយ តាមរយៈការដាក់បញ្ចូលនូវ “ធាតុផ្សំបទល្មើសថ្មី” ប៉ុន្តែអនុញ្ញាតផ្លាស់ប្តូរការកំណត់អង្គច្បាប់លើអង្គហេតុ (តាមរយៈការកែប្រែ “ការកំណត់អង្គច្បាប់ទៅលើបទល្មើស”)។ ដោយកាត់បន្ថយការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើ “បទបញ្ញត្តិដែលថា គ្មានធាតុផ្សំថ្មីនឹងត្រូវដាក់បញ្ចូល” ថាជាការធ្វើម្តងទៀតនូវ “ដែនកំណត់ដែលបានបង្កើតយ៉ាងត្រឹមត្រូវ ... ចំពើការកំណត់បទចោទឡើងវិញ មិនត្រូវធ្វើអោយហួសពីអង្គហេតុដែលមានក្នុងឯកសារចោទប្រកាន់”[35] នេះគឺជា អ្វីដែលវិធានត្រូវបានបកស្រាយដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី០០១[36] ។

២១. បើសិនជា ការបកស្រាយរបស់ កសព ត្រឹមត្រូវ ការណ៍នេះនឹងប៉ះពាល់ដល់លទ្ធភាពរបស់ភាគីទាំងអស់ អោយមានភាពប្រាកដប្រជានៅក្នុងច្បាប់ជាធរមាន។ អង្គជំនុំជម្រះសាលាដំបូង អាចរង់ចាំរហូតដល់ចុងបញ្ចប់នៃការជំនុំជម្រះក្តី ដ៏វែងអន្លាយ ដើម្បីសម្រេចទៅលើការផ្លាស់ប្តូរនូវធាតុផ្សំ

---

[34] សំណើរំលោភសេពសន្ថវៈCAH ជើងទំព័រ ៩។

[35] *រឿងក្តី កាំងហ្គេចអ៊ាវ ហៅ “ឌុច”* 001/18-07-2007-អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ កក្កដា ២០១០ ឯកសារ E188, កថាខណ្ឌ ៤៩៤។ ថ្វីបើមេធាវីការពារក្តី យល់ស្របថាវាមានដែនកំណត់ដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ មិនត្រូវធ្វើអោយហួសពីអង្គហេតុដែលមានក្នុងឯកសារចោទប្រកាន់ សូមអះអាងថា ដែនកំណត់នេះគឺតាមពិតត្រូវបានរួមបញ្ចូលនៅក្នុងឃ្លាទី២ នៃវិធាន ៩៨(២) តាមរយៈពាក្យពេចន៍ “ដូចមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ”។ ការរិតត្បិតទៅការបន្ថែម “ធាតុផ្សំ”ថ្មី ទាក់ទងទងនឹងធាតុផ្សំអង្គច្បាប់។ ផ្ទុយពីការអះអាងពីសារណារបស់ កសព ការបកស្រាយនេះគឺធានាថា គ្មានពាក្យពេចន៍ណាមួយនៃឃ្លាទី២ នៃវិធាន ៩៨(២) ចែងហួសហេតុនោះឡើយ។ *សូមមើល* សំណើរំលោភសេពសន្ថវៈCAH ជើងទំព័រ ៩។ ផ្ទុយពីការបកស្រាយរបស់ កសព (និងការបកស្រាយរបស់អង្គជំនុំជម្រះ សាលាដំបូង ក្នុងករណី ឌុច) ដែលធ្វើអោយពាក្យពេចន៍ “ដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ” នៅក្នុងឃ្លាទី ២ នៃវិធាន ៩៨(២) ដែលហួសហេតុ។

[36] មូលដ្ឋានសម្រាប់ការផ្លាស់ប្តូរការកំណត់អង្គហេតុនៅចំពោះមុខ អវតក គឺវិធាន ៩៨(២) ដែលចែងអំពីចំណុចនេះ ដើម្បីការពារការជំនុំជម្រះដោយយុត្តិធម៌” *រឿងក្តី កាំងហ្គេចអ៊ាវ ហៅ “ឌុច”* 001/18-07-2007-អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ កក្កដា ២០១០ ឯកសារ E188 នៅកថាខណ្ឌទី ៤៩៥ ។ បទបញ្ជាផ្ទៃក្នុងរបស់តុលាការ ICC ក៏អនុញ្ញាតស្រដៀងនេះឲ្យអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការនេះកែប្រែការកំណត់បទចោទ បន្ទាប់ពីនីតិវិធីជំនុំជម្រះចាប់ផ្តើម” ។ ដូចខាងលើ (បញ្ជាក់បន្ថែម) ។

នៃបទល្មើស ដរាបណាសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនជាប់ចោទមិនមានការប៉ះពាល់។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង អាចរង់ចាំរហូតដល់សាលក្រមដើម្បីបន្ថែមធាតុផ្សំបន្ថែមទៀតទៅលើច្បាប់ជាធរមាន ដែល កសព ដែល កសព នឹងប្រហែលជាមិនបានដឹងនៅក្នុងអំឡុងពេលជំនុំជម្រះ ហើយប្រហែលជាមិនអាចប៉ុនប៉ងដើម្បីបង្ហាញភស្តុតាង។ រឿងនេះមិនអាចជាការបកស្រាយដោយត្រឹមត្រូវ លើវិធាន ៩៨ ឡើយ។ មន្ទិលសង្ស័យណាមួយនៅក្នុងការបកស្រាយត្រឹមត្រូវនៃវិធាននេះ ត្រូវបានដោះស្រាយជាប្រយោជន៍ដល់ ជនជាប់ចោទ[37] ។

២២. ទី ២ វិធាន ៩៨ (២) មិនអនុញ្ញាតចំពោះការកែប្រែការកំណត់បទចោទនៃទម្រង់នៃការទទួលខុសត្រូវ។ វិធាននេះលើកឡើងថា អង្គជំនុំជម្រះអាច "ប្ដូរការកំណត់នៃបទបចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"[38]។ សហឧក្រិដ្ឋកម្មរួម មិនមែនជាបទល្មើស ប៉ុន្តែជាទម្រង់នៃការទទួលខុសត្រូវ។ ក្នុងរឿងក្ដី ០០១ អង្គជំនុំជម្រះរឿងក្ដីរបស់ឌុច បានកំណត់ថា វិធាន ៩៨ (២) មិនបានអនុញ្ញាតចំពោះការកែការកំណត់បទចោទនៃទម្រង់នៃការទទួលខុសត្រូវទេ ប៉ុន្តែបានកំណត់ថាសមត្ថភាពក្នុងការកែប្រែការកំណត់បទចោទនៃទម្រង់ មិនត្រូវបានប្រឆាំងតវ៉ាដោយភាគីឡើយ[39]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា វាស្ថិតនៅក្រោមអំណាចនៃវិធាន ៩៨ (២) ដើម្បីកែប្រែការកំណត់បទចោទនៃទម្រង់នៃការទទួលខុសត្រូវ ព្រោះបទបញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ "បានអនុញ្ញាតចំពោះការកែប្រែការកំណត់បទចោទ លើអង្គហេតុ ដោយអនុលោមតាមទម្រង់នៃការចូលរួមខុសគ្នា"[40]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "នៅពេលដែលបទបញ្ញត្តិច្រើននៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលអាចប្រៀបធៀបគ្នាបាន មិនបង្ហាញឱ្យបានច្បាស់លាស់ពីការកែប្រែទម្រង់នៃការទទួលខុសត្រូវ អង្គជំនុំជម្រះយល់ស្របថាការកែប្រែប្រភេទនេះ អាចត្រូវបានអនុញ្ញាតនៅ

---

[37] ករណីមានវិមតិសង្ស័យ អង្គជំនុំជម្រះសាលាដំបូងត្រូវតែគោរពគោលការណ៍រដ្ឋធម្មនុញ្ញគឺ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* អនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មឆ្នាំ ១៩៩៩។

[38] គូសបញ្ជាក់បន្ថែម ។

[39] *សូមមើល រឿងក្ដី កាំងហ្គេចអ៊ាវ ហៅ "ឌុច"* 001/18-07-2007-អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ កក្កដា ២០១០ ឯកសារ E188កថាខណ្ឌ ៤៩៣។

[40] *ដូចជើងទំព័រខាងលើ* លេខយោង ៨៦៧។

ក្រោមវិធាន ៩៨ (២) នៃវិធានផ្ទៃក្នុង[41]។" អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាឡើងវិញ អំពីការសន្និដ្ឋានក្នុងរឿងក្តី ០០១ នេះ ព្រោះច្បាប់កម្ពុជាជាធរមាន មិនអនុញ្ញាតចំពោះការ កែប្រែការកំណត់បទចោទនេះទេ[42] និងពីព្រោះពាក្យពេចន៍នៅក្នុងវិធាន ៩៨ (២) ខុសពីនៅក្នុង បទបញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

២៣. កាលណាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើសុំនានារបស់ ក.ស.ព មិនមែនជា អញ្ញត្រកម្មនិងត្រូវលើកឡើងនៅដំណាក់កាលនេះ *និង* យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានយុត្តាធិការក្នុងការផ្លាស់ប្តូរច្បាប់ជាធរមាននៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការ កែប្រែការកំណត់បទចោទបាន[43] តែក្នុងករណីដែល ការកំណត់នេះមិនបំពានលើសិទ្ធិទទួលបាន ការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ។ វាជាការជាក់ស្តែង ដែលការធ្វើបែបនេះគឺជា ការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់ជនជាប់ចោទ ចំពោះការ យកមកអនុវត្តនូវបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ ដែលមិនមានចែងនៅក្នុងច្បាប់ជាធរមាន នៅអំឡុងពេលពាក់ព័ន្ធ។ បញ្ហានេះនឹងបង្ហាញក្នុងការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹង សំណើសុំនានារបស់ ក.ស.ព ប្រសិនបើជាការចាំបាច់សម្រាប់ការឆ្លើយតបបែបនេះ។

## III. សំណើសុំអោយមានពេលវេលាបន្ថែម

២៤. មេធាវីការពារក្តីស្នើដល់អង្គជំនុំជម្រះសាលាដំបូង សូមផ្តល់ពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹង សំណើនានារបស់ កសព រហូតដល់ ២២ សីហា ២០១១ បើសិនជា អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា សំណើនានារបស់ កសព អាចទទួលយកបាននៅដំណាក់កាលនេះ។ ការបន្ថែម ពេលវេលានេ គឺចាំបាច់ដោយហេតុថា មេធាវីការពារក្តី ត្រូវតែឆ្លើយតបទៅនឹងសំណើនានាទាំងបី របស់ កសព ហើយក៏ត្រូវត្រៀមដើម្បីដាក់ឯកសារផ្សេងទៀតផងដែរ[44] ដែលកាលបរិច្ឆេទកំណត់

---

[41] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៤៩៣។

[42] អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា "បទបញ្ញត្តិស្រដៀងគ្នានៅក្នុងប្រព័ន្ធច្បាប់កម្ពុជាមិនដោះស្រាយជាក់លាក់ ការផ្លាស់ប្តូរនៃទម្រង់នៃការទទួលខុសត្រូវឡើយ ..." *ដូចដើងទំព័រខាងលើ* ។

[43] ដូចដើងទំព័រខាងលើ កថាខណ្ឌ៤៩០។

[44] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសារណារបស់ សហព្រះរាជអាជ្ញាស្តីពីអាជ្ញាយុកាលនៃបទល្មើសជាតិ ចុះថ្ងៃទី ២៧ ឧសភា ២០១១ ឯកសារ E51/7/1 ត្រូវផុតកំណត់ថ្ងៃទី ១៧ មិថុនា ២០១១, បញ្ជីអ្នកជំនាញរបស់មេធាវីការពារក្តីទៅតាម លំដាប់លំដោយនៃភាពពាក់ព័ន្ធ និងមូលហេតុនានាថាហេតុអ្វី បានជាអ្នកជំនាញទាំងនេះត្រូវបានចុះក្នុងបញ្ជីទៅតាមលំដាប់

ដាក់ឯកសារស្ថិតក្នុងអំឡុងពេលដែល អង្គជំនុំជម្រះសាលាដំបូង បានផ្តល់អោយសម្រាប់ការឆ្លើយតបនានា ហើយត្រូវតែត្រៀមបន្ថែមទៀតសម្រាប់ការបង្ហាញនូវសារណាផ្ទាល់មាត់ ដែលនឹងត្រូវលើកឡើងនាពេលសវនាការបឋមទាក់ទងនឹង *គោលការណ៍គ្មានការណ៍កាត់ពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*), ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស, អាជ្ញាយុកាលសម្រាប់បទល្មើសអំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរ និងការអនុវត្តនូវបទល្មើសជាតិតាមមាត្រា ៣ថ្មីនៃច្បាប់បង្កើត អវតក ។ សារណាទាំងអស់នេះបកស្រាយនូវបញ្ហាសំខាន់ៗជាសារវ័ន្តជាច្រើនដល់មេធាវីការពារក្តី ព្រោះថាបញ្ហាទាំងនេះអោយបណ្តាលអោយ អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចថា អង្គជំនុំជម្រះសាលាដំបូង គ្មាន (ឬ មានដែនកំណត់) យុត្តាធិការដើម្បីកាត់ទោសលោក អៀង សារី។ ហេតុដូច្នេះ ពេលច្រើនបំផុតត្រូវចំណាយដើម្បីត្រៀមរៀបចំសម្រាប់បញ្ហានេះ។ ម្យ៉ាងវិញទៀត កសព ត្រូវមានចេតនាក្នុងការដាក់នូវសំណើរបស់ខ្លួន ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាំងពីថ្ងៃទី ១៣ មករា ២០១១ នៅពេលដែលអង្គបុរេជំនុំជម្រះ បានជូនដំណឹងដល់ភាគីថា ទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធគឺជាធាតុផ្សំរួម (chapeau element) សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយ ការរំលោភសេពសន្ថវៈមិនមែនជាអំពើជាបទល្មើសក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធឡើយ[45]។ កសព ត្រូវតែមានចេតនាដើម្បីដាក់នូវសំណើរបស់ខ្លួនផងដែរទាក់ទងនឹង JCE តាំងពីថ្ងៃទី ២០ ឧសភា ជាថ្ងៃដែល កសព ត្រូវបានជូនដំនឹងថា JCE III មិនអាចយកមកអនុវត្តបាននៅ អវតក[46] ។ បើសិនជា កសព បានដាក់នូវសំណើនានារបស់ខ្លួនអោយទាន់ពេលត្រឹមត្រូវនោះ មេធាវីការពារក្តីនឹងមិនស្ថិតនៅក្នុងស្ថានភាពលំបាកខ្វាយខ្វល់បែបនេះឡើយ។ វាទំនងជាថា កសព បានដាក់ឯកសារនាពេលជាក់លាក់ស្ទើរតែកៀកនឹងសវនាការបឋម នេះដើម្បីទទួលបាននូវផលចំណេញ។ ការស្នើសុំពេលវេលាបន្ថែម នឹងមិនបង្កអោយមានការអូសបន្លាយពេលដោយមិន

---

លំដោយបែបនេះ ត្រូវផុតកំណត់ថ្ងៃទី ២០ មិថុនា ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងសារណារបស់ កសព អនុលោមទៅតាមវិធាន ៩២ ទាក់ទងនឹងការទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ មិថុនា ២០១១ ឯកសារលេខ E96 ត្រូវផុតកំណត់ថ្ងៃទី ២២ កក្កដា ២០១១ ហើយ បញ្ជីឯកសាររបស់មេធាវីការពារក្តី សម្រាប់ប្រធានបទជំនុំជម្រះក្តីចំនួនបួនដំបូង ត្រូវផុតកំណត់នៅថ្ងៃទី ២២ កក្កដា ២០១១។

[45] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ មករា ២០១១ ឯកសារលេខ D427/1/26។

[46] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពី សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ឧសភា ២០១០ ឯកសារលេខ D97/14/15។

សមហេតុផល ឬ ការលំបាក់ខូចខាតដល់ភាគីណាមួយឡើយ មិនដូចសារណានានារបស់ កសព ឡើយ។

## III. **ការស្នើរកដំណោះស្រាយ**

**អាស្រ័យហេតុដូច្នេះ** ដូចហេតុផលទាំងអស់ដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើដោយគោរព ឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ចេញ**សេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចលើកឡើង សំណើរបស់សហព្រះរាជអាជ្ញានៅដំណាក់កាលនេះដែរ ឬអត់ និង/ឬ

ខ. **យល់ឃើញ**ថាសំណើរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបានទេ ឬ

គ. **អនុញ្ញាត**អោយមានការបន្ថែមពេលវេលាសម្រាប់ការឆ្លើយតប ទៅនឹងសំណើសុំនានា របស់ កសព រហូតដល់ថ្ងៃទី ២២ សីហា ២០១១។

សូមថៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១**

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**